

Planting Seeds of Growth
We are ÆON

# របាយការណ៍ប្រចាំឆ្នាំ
# ANNUAL REPORT
# 2022



## AEON CARD
នេះជាអ្វីដែលអ្នកត្រូវការ




ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
ÆON SPECIALIZED BANK (CAMBODIA) PLC.

# មាតិកា

**“ សាមញ្ញ រហ័ស និង ងាយស្រួល ”**

អ៊ីអន យើងតែងតែផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែល សាមញ្ញ រហ័សនិងងាយស្រួល


០៤ រចនាសម្ព័ន្ធនៃអ៊ីអនគ្រុប/ អេអេហ្វអេសគ្រុប

០៦ សង្ខេបព័ត៌មានហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២២

០៧ សារពីគណៈគ្រប់គ្រង

០៨ ក្រុមប្រឹក្សាភិបាល

១០ តារាងរចនាសម្ព័ន្ធ ចាត់តាំង

១១ ប្រវត្តិអាជីវកម្ម

១២ សមិទ្ធិផលឆ្នាំ២០២២

១៣ សង្ខេបព័ត៌មានអាជីវកម្ម សំខាន់ៗឆ្នាំ២០២២

១៤ សង្ខេបព័ត៌មានអាជីវកម្ម សំខាន់ៗឆ្នាំ២០២៣

១៥ ការត្រួតពិនិត្យផ្ទៃក្នុង

១៦ ទំនួលខុសត្រូវ ផ្នែកសង្គមរបស់ក្រុមហ៊ុន

១៧ របាយការណ៍ស្ថានភាព ហិរញ្ញវត្ថុ

១៨ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

១៩ របាយការណ៍បម្រែបម្រួល មូលធន

២០ របាយការណ៍លំហូរ សាច់ប្រាក់

២២ កំណត់សម្គាល់លើ របាយការណ៍ហិរញ្ញវត្ថុ

៤០ អំពីអ៊ីអនគ្រុប

# បណ្ដាញនៃសម្ព័ន្ធក្រុមហ៊ុនអ៊ីអនហ្វាយនែនសលសឺវីស

*“ជួយលើកកម្ពស់ជីវភាពរស់នៅរបស់អតិថិជន និងធ្វើឱ្យពួកគាត់ទទួលបាននូវកាលានុវត្តភាពនាពេលអនាគតជាអតិបរមាតាមរយៈការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធភាពខ្ពស់”*



# រចនាសម្ព័ន្ធនៃអ៊ីអនគ្រុប/អេអេហ្វអេសគ្រុប

- International Business
- Services & Specialty Store Business
- Shopping Center Development Business
- **Financial Services Business**
- Health & Wellness Business
- Supermarket Business
- General Merchandise Store Business

ÆON








# FINANCIAL SERVICES BUSINESS

- AFS Corporation Co.,Ltd.
  - AEON Specialized Bank (Cambodia) Plc.
  - AEON Credit Service (Phillippines) Inc.
  - AEON Housing Loan Service Co.,Ltd.
  - AEON Bank.,Ltd.
- Consolidated Subsidiaries Overseas
  - AEON Allianz Life Insurance Co.,Ltd.
  - ACS Leasing Co.,Ltd.
  - AEON Product Finance.,Ltd.
  - AEON S.S. Insurance Co.,Ltd.
  - ACS Credit Management Co.,Ltd.
  - AEON Insurance Service Co.,Ltd.
  - AEON Credit Service Co.,Ltd.



# សង្ខេបព័ត៌មានហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២២

## សាវតារបស់យើង

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ("ក្រុមហ៊ុន") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានម្រិត នៅប្រទេសកម្ពុជា ដែលបានចុះបញ្ជីដំបូងនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ក្រោមបញ្ជីការលេខ Co.២៣៨០E/២០១១ ចេញដោយក្រសួងពាណិជ្ជកម្ម និងបានចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម ក្រោមលេខចុះបញ្ជីការថ្មីលេខ ០០០០៦៣៨៤។ នៅថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១១ ក្រុមហ៊ុនក៏បានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យើងគឺជាអ្នកនាំមុខគេទីមួយក្នុងទីផ្សារកម្ពុជា ដែលផ្តល់ជូនអតិថិជននូវសេវាបង់រំលស់ដោយមិនទាមទារឲ្យមានទ្រព្យធានា ដូចជាផលិតផលប្រើប្រាស់ក្នុងផ្ទះ ម៉ូតូ ទូរស័ព្ទដៃ កម្ចីផ្ទាល់ខ្លួន និងសម្ភារៈកសិកម្ម។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ យើងទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា។ ចាប់ពីពេលនោះមកយើងបានកម្លាយខ្លួនទៅជាធនាគារឯកទេស និងចាប់ផ្តើមពង្រីកអាជីវកម្មរបស់យើងដោយចេញប័ណ្ណឥណទាន អ៊ីអនរ៉ែលឡេត អ៊ីអនកាតម៉ូបាល (m-Visa) ជូនអតិថិជន។

ឆ្នាំ២០១៩ ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl. ដែលជាក្រុមហ៊ុនបានចុះឈ្មោះក្នុងទីផ្សារភាគហ៊ុនប្រទេសថៃ កាន់កាប់ភាគហ៊ុនចំនួន ៥០% ហើយភាគហ៊ុនចំនួន ៥០% ផ្សេងទៀតកាន់កាប់ដោយក្រុមហ៊ុន AFS Corporation Co., Ltd. ("AFSC") ជាក្រុមហ៊ុនឯកជនគ្រប់គ្រង១០០% ដោយ AEON Financial Service Co., Ltd. ("AFS") ដែលបានចុះបញ្ជីនៅក្នុងទីផ្សារភាគហ៊ុនជប៉ុន។

## ទិន្នន័យហិរញ្ញវត្ថុសំខាន់

**ការលក់សរុប** (ឯកតា: '000ដុល្លារ)




**ប្រាក់ចំណូលសរុប** (ឯកតា: '000ដុល្លារ)




**គណនេយ្យទទួល** (ឯកតា: '000ដុល្លារ)




**ទ្រព្យសកម្មសរុប** (ឯកតា: '000ដុល្លារ)




**ចំនួនបុគ្គលិក**




**ចំនួនសាខា**




របាយការណ៍ហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នេះត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបង្ហាញ ជាលើកដំបូង ដោយអនុលោម តាមស្តង់ដារ របាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។

កំណត់សម្គាល់៖ ចាប់តាំងពីការិយបរិច្ឆេទដំបូង រហូតដល់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុវត្តតាមស្តង់ដារគណនេយ្យនៃកម្ពុជា និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងគណនេយ្យផ្សេងៗ រួមទាំងបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

# សារពីគណៈគ្រប់គ្រង




**លោក Junji Noda**

*អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក*

**យើងសូមណែនាំឲ្យស្គាល់ពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនយើង នៅក្នុងទីផ្សាររបស់ព្រះរាជាណាចក្រកម្ពុជាជាមួយនឹងពាក្យស្លោក**

## “ សាមញ្ញ រហ័ស និង ងាយស្រួល ”

### *អ្នកអានជាទីគោរព*

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជាក្នុង ខែតុលា ឆ្នាំ ២០១១ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលចាប់ផ្តើមជាមួយនឹងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដោយមិនមានទ្រព្យធានា។ យើងបានទទួលអាជ្ញាប័ណ្ណធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា នៅ ខែតុលា ឆ្នាំ ២០១៥ ។

កូវីដ១៩ ជាជម្ងឺរាតត្បាតសកល ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ទិដ្ឋភាពអាជីវកម្មដែលនាំឲ្យមាននូវការផ្លាស់ប្តូរជាច្រើន។ ហើយការផ្លាស់ប្តូរនេះ នៅតែបន្ត ទោះបីជាជំងឺរាតត្បាតបានស្រាកស្រាន្តហើយក៏ដោយ។ នៅក្នុងប្រទេសកម្ពុជា យើងឃើញមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ក្នុងការធ្វើអាជីវកម្ម ជាពិសេសការផ្លាស់ប្តូរផ្នែកឌីជីថលនៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងសេវាកម្មហិរញ្ញវត្ថុដោយ មានការរួមចំណែកយ៉ាងសំខាន់ពីបច្ចេកវិទ្យាឌីជីថល។

ជាលទ្ធផល ប្រតិបត្តិការអនឡាញបានកើនឡើងយ៉ាងគំហុក ដែលនាំមកនូវកាលានុវត្តភាពថ្មីៗសម្រាប់ប្រទេសកម្ពុជា និងក្រុមហ៊ុនរបស់យើង។ ធុរកិច្ចនៅកម្ពុជាពីមុន ភាគច្រើនផ្អែកលើសាច់ប្រាក់ ជាពិសេសក្នុងចំណោមប្រតិបត្តិការអាជីវកម្មខ្នាតតូច។ នៅក្នុងរយៈពេលក្រោយការរាតត្បាតនេះ យើងអាចមើលឃើញថាការទូទាត់ និងការទទួលការទូទាត់ដោយគ្មានសាច់ប្រាក់បានកើនឡើងគួរឱ្យកត់សម្គាល់ ហើយអតិថិជនបានសម្របខ្លួនទៅតាមការផ្លាស់ប្តូរនេះយ៉ាងរហ័ស។ រាល់ប្រតិបត្តិការទូទាត់ គឺត្រូវបានធ្វើឡើងតាមរយៈកម្មវិធីទូរស័ព្ទដៃ មិនត្រឹមតែនៅផ្សារទំនើបប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅតាមអាជីវកម្មខ្នាតតូចផងដែរ។ អតិថិជនចាប់ផ្តើមទម្លាប់នឹងការប្រើប្រាស់កាត ឬកម្មវិធីទូរស័ព្ទ សម្រាប់ការទូទាត់ ដែលធ្វើឲ្យពួកគេអាចគ្រប់គ្រងថវិកា ឬការចំណាយថវិការបស់ពួកគេបានយ៉ាងល្អ។

អំឡុងពេលប្រឈមនឹងបញ្ហាដែលបង្កឡើងដោយជម្ងឺរាតត្បាត យើងបានជួបប្រទះឧបសគ្គជាច្រើន។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមទាំងនេះបានផ្តល់នូវការយល់ដឹង និងមេរៀនដែលមិនអាចកាត់ថ្លៃបានដែលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់យើង។ តាមរយៈវិធានការបុរេសកម្ម យើងបានបង្ហាញពីការសម្របខ្លួន និងភាពធន់ ដែលអនុញ្ញាតឱ្យយើងអាចយកឈ្នះលើឧបសគ្គទាំងនេះ និងថែមទាំងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់យើងផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព និងធានាបាននូវការកែលម្អជាបន្តបន្ទាប់ យើងបានអនុវត្តផែនការយថាភាពអាជីវកម្មដ៏ទូលំទូលាយមួយ។ ផែនការនេះ ជួយឱ្យយើងឆ្លើយតបយ៉ាងឆាប់រហ័សចំពោះបញ្ហាដែលអាចកើតមាន កាត់បន្ថយផលប៉ះពាល់ និងការពារដំណើរការអាជីវកម្មរបស់យើង។

ទោះបីជាមានការលំបាកទាំងនេះក៏ដោយ គម្រោងកម្មវិធីឌីជីថល ឬកម្មវិធីទូរស័ព្ទដែលមានមុខងារច្រើនដើម្បីបង្កើនការពេញចិត្តរបស់អតិថិជន ប្រកបភាពងាយស្រួល ស្វ័យសេវាកម្ម ដោយប្រើត្រឹមចុងម្រាមដៃរបស់អតិថិជន គឺស្ថិតនៅក្នុងផែនការអភិវឌ្ឍរបស់យើង។ នេះគឺជាការផ្តល់សេវាកម្មគ្រប់យ៉ាងនៅកន្លែងតែមួយ ដែលរួមបញ្ចូលការដាក់សំណើសុំកម្ចី ការទូទាត់ ការគ្រប់គ្រងការចំណាយរួមជាមួយកម្មវិធីសន្សំពិន្ទុ ដើម្បីបំពេញចិត្តអតិថិជន និងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរទាំងនេះ។

យើងនឹងបន្តពង្រឹងកម្មវិធីរបស់យើងដែលមានដូចជា "អ៊ីអនវ៉លឡែត" "អ៊ីអនកាតម៉ូបាល" និង "អ៊ីអនរហ័ស" ដើម្បីបង្កើនភាពងាយស្រួលដល់អតិថិជន។ បន្ថែមទៅលើការឆ្លើយតបទៅនឹងការផ្លាស់ប្តូរឌីជីថល ក្រុមហ៊ុនយើងខ្ញុំ ក្នុងនាមជាសមាជិកអ៊ីអនគ្រុប មានចំណុចខ្លាំង គឺយើងមាន “ហាងជាក់ស្តែង” ហើយយើងបានប្តេជ្ញាថា នឹងផ្តល់នូវអ្វីដែលខុសប្លែកពីស្ថាប័នហិរញ្ញវត្ថុដទៃ ព្រមទាំងផ្តល់នូវសេវាកម្មកាតឥណទាន និងផលិតផលហិរញ្ញវត្ថុដល់ដែលលោកអ្នកដែលជា “អតិថិជនដ៏មានតម្លៃ” របស់យើង។

ជាលទ្ធផល យើងទទួលបាននូវពានរង្វាន់ឈានមុខពីវីសា លើចំនួនប្រតិបត្តិការកាតឥណទាន (ឆ្នាំ២០២១) និង (ឆ្នាំ២០២២) និងអត្រាបើកការប្រើប្រាស់កាតច្រើន (ឆ្នាំ២០២១) ដែលវាបានមកពីការគាំទ្ររបស់អតិថិជន។

យើងនឹងបន្តផ្តល់នូវភាពងាយស្រួល និងគុណតម្លៃដល់អតិថិជនដើម្បីរួមចំណែកដល់បរិយាបន្នហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា និងដើម្បីបំពេញតម្រូវការ និងជីវភាពប្រចាំថ្ងៃរបស់អតិថិជន តាមរយៈការទូទាត់ដោយប្រើប្រាស់កាតឥណទាន។

ជាចុងក្រោយ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី គឺស្ថិតនៅចំណុចល្អក្នុងការចាប់យកឱកាសផ្នែកសេវាកម្មឌីជីថលថ្មីអនុវត្តមេរៀនដែលបានរៀនពីជម្ងឺរាតត្បាត និងដោះស្រាយបញ្ហាប្រឈម តាមរយៈផែនការយថាភាពអាជីវកម្មដ៏រឹងមាំរបស់យើង។ យើងនឹងរក្សាទំនាក់ទំនងដ៏រឹងមាំជាមួយអតិថិជនរបស់យើង។ យើងសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអតិថិជន ដៃគូអាជីវកម្ម និងសហការីរបស់យើងចំពោះការគាំទ្រ និងការរួមចំណែកជាបន្តបន្ទាប់របស់ពួកគេចំពោះការអភិវឌ្ឍរបស់យើងក្នុងឆ្នាំ ២០២២។

野田 潤史

**លោក Junji Noda**

អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

# ក្រុមប្រឹក្សាភិបាល



## លោក Tsutomu Omodera

*មុខតំណែង ៖ ប្រធានក្រុមប្រឹក្សាភិបាល*
*ឆ្នាំកំណើត ៖ ១៩៦៤*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រផ្នែកវិស្វកម្ម នៅសាកលវិទ្យាល័យ Kobe ប្រទេសជប៉ុន*

**២០២១ - បច្ចុប្បន្ន ៖**
ប្រធានក្រុមប្រឹក្សាភិបាលរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២០ - បច្ចុប្បន្ន ៖**
អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយករបស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០២០ - បច្ចុប្បន្ន ៖**
អភិបាលមិនប្រតិបត្តិ (កាន់តួនាទីជាប្រធាន) របស់ក្រុមហ៊ុន ACS Servicing (Thailand) Co., Ltd.

**២០១៨ - ២០២០ ៖**
អគ្គនាយករបស់ក្រុមហ៊ុន ACS Credit Management Co., Ltd. (ជប៉ុន)

**២០១៩ ៖**
អភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.

**២០១៥ - ២០១៩ ៖**
អភិបាល និងប្រធានប្រតិបត្តិ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.



## លោក Junji Noda

*មុខតំណែង ៖ អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក របស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី*
*ឆ្នាំកំណើត ៖ ១៩៧១*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Kansai ប្រទេសជប៉ុន*

**២០២២ - បច្ចុប្បន្ន ៖**
អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក របស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - ២០២២ ៖**
អភិបាលប្រតិបត្តិ នៃ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០១៥ - ២០២១ ៖**
អនុប្រធានប្រតិបត្តិរបស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០១៣ - ២០១៥ ៖**
ប្រធានគ្រប់គ្រងជាន់ខ្ពស់ របស់ក្រុមហ៊ុន AEON Credit Service (ASIA) Co., Ltd

**២០០០ - ២០១៣ ៖**
ប្រធានគ្រប់គ្រងទូទៅ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.



## លោក Shuji Taniguchi

*មុខតំណែង ៖ អភិបាលប្រតិបត្តិ*
*ឆ្នាំកំណើត ៖ ១៩៧៥*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យ Seikei ប្រទេស ជប៉ុន*

**២០២២ - បច្ចុប្បន្ន ៖**
អភិបាលប្រតិបត្តិរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - ២០២២ ៖**
អ្នកគ្រប់គ្រងទូទៅ នាយកដ្ឋាន Group Corporate Sales Promotion របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.

**២០១៨ - ២០២១ ៖**
ប្រធានសាខានៃ AEON Credit Service Co., Ltd.

**២០០២ - ២០១៨ ៖**
បុគ្គលិកទទួលបន្ទុកផ្នែកសេវាហិរញ្ញវត្ថុ របស់ក្រុមហ៊ុន AEON Credit Services Co., Ltd.



## លោក Masato Anada

*មុខតំណែង ៖ អភិបាលមិនប្រតិបត្តិ*
*ឆ្នាំកំណើត ៖ ១៩៦៧*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Yokohama National University ប្រទេស ជប៉ុន*

**២០២២ - បច្ចុប្បន្ន ៖**
អភិបាលមិនប្រតិបត្តិនៃ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២០ - បច្ចុប្បន្ន ៖**
អភិបាលរបស់ក្រុមហ៊ុន AFS Corporation Co., Ltd.

**២០១២ - ២០២០ ៖**
មន្ត្រីប្រតិបត្តិផ្នែក គ្រប់គ្រងហានិភ័យ នីតិកម្ម និងប្រតិបត្តិតាមនៃ AEON Bank, Ltd..

# អ្នកប្រឹក្សា



## លោក អោម សេងបូរ៉ា

*មុខតំណែង ៖ អភិបាលឯករាជ្យ*

*ឆ្នាំកំណើត ៖ ១៩៧៧*

*កម្រិតវប្បធម៌ ៖ បណ្ឌិតកិត្តិយសផ្នែកគ្រប់គ្រងពាណិជ្ជកម្ម*

**២០១៩ - បច្ចុប្បន្ន ៖**
ប្រធានក្រុមប្រឹក្សាភិបាលនៃ CEO Master Club Investment Plc.

**២០១៥ - បច្ចុប្បន្ន ៖**
ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស៊ីអ៊ីអូ រួមមាន ស៊ីអ៊ីអូម៉ាស្ទ័រក្លឹប សាលាអចលនទ្រព្យកម្ពុជា និងមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ

**២០១៣ - បច្ចុប្បន្ន ៖**
ក្រុមប្រឹក្សាភិបាលឯករាជ្យនៃរដ្ឋាករ ទឹកស្វយ័តក្រុងភ្នំពេញ

**២០១២ - បច្ចុប្បន្ន ៖**
សមាជិកទីប្រឹក្សានៃសភាពាណិជ្ជកម្មកម្ពុជា

**២០១១ - បច្ចុប្បន្ន ៖**
ក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី



## លោកស្រី ខៀវ មាលី

*មុខតំណែង ៖ អភិបាលឯករាជ្យ*

*ឆ្នាំកំណើត ៖ ១៩៦៤*

*កម្រិតវប្បធម៌ ៖ បរិញ្ញាប័ត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Libre de Bruxelles (ULB) និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដោយសហការជាមួយសាកលវិទ្យាល័យ Montreal និង សាកលវិទ្យាល័យហ្សឺណែវ (LLM) និង LLB មកពីសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បរិញ្ញាបត្រច្បាប់នៅវិទ្យាស្ថានជាតិគ្រប់គ្រង និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច។*

**២០២២ - បច្ចុប្បន្ន ៖**
អ្នកសម្របសម្រួលនៃ CEDR

**២០១៩ - បច្ចុប្បន្ន ៖**
អនុប្រធាន និងសមាជិកស្ថាបនិកនៃ មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**២០១៧ - បច្ចុប្បន្ន ៖**
សមាជិកនៃ APAA and Council Member of APAA-Cambodian Group

**២០១៦ - បច្ចុប្បន្ន ៖**
សមាជិកនៃ ASEAN IPA- Country Head of Cambodian Group

**២០១៤ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០១២ - បច្ចុប្បន្ន ៖**
សហប្រធាននៃការិយាល័យនៃ SokSiphana & associates, សមាជិកនៃ ZICOLAW

**២០០៩ - បច្ចុប្បន្ន ៖**
ភ្នាក់ងារម៉ាកពាណិជ្ជកម្ម

**២០០៩ - បច្ចុប្បន្ន ៖**
សមាជិកស្ថាបនិកនៃ សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា (IPAC)

**២០០៤ - បច្ចុប្បន្ន ៖**
សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា



## ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា

*មុខតំណែង ៖ ទីប្រឹក្សា*

*ឆ្នាំកំណើត ៖ ១៩៦០*

*កម្រិតវប្បធម៌ ៖ បណ្ឌិតច្បាប់ (JD) មហាវិទ្យាល័យសាកលវិទ្យាល័យនីតីសាស្ត្រនៃ Widener University School of Law Delaware, (USA) បណ្ឌិតផ្នែកទស្សនវិជ្ជា (Ph.D) នៃ Bond University School of Law Queensland (Australia) បន្ទប្បន្នកំពុងបន្តការសិក្សា(Ph.D.) នៃសាកលវិទ្យាល័យ Paris 2 Pantheon Assas លើច្បាប់ប្រៀបធៀប*

**២០១៨ - បច្ចុប្បន្ន ៖**
ជាប្រធាននៃ Asian Vision Institute

**២០១៨ - បច្ចុប្បន្ន ៖**
ទីប្រឹក្សាជាន់ខ្ពស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**២០១៤ - បច្ចុប្បន្ន ៖**
ទីប្រឹក្សានៃ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០០៩ - បច្ចុប្បន្ន ៖**
ដៃគូគ្រប់គ្រង SokSiphana & associates ដែលជាសមាជិករបស់ ZICOLaw

**១៩៩៨ - បច្ចុប្បន្ន ៖**
សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# តារាងរចនាសម្ព័ន្ធចាត់តាំង



# ប្រវត្តិអាជីវកម្ម

## ២០១៥



តុលា ទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស
វិច្ឆិកា ដាក់ឱ្យដំណើរការពាក្យស្នើសុំតាមប្រព័ន្ធ Online

## ២០១៦






កុម្ភៈ កម្លាយខ្លួនទៅជាធនាគារឯកទេស
មេសា កែលំអសាខាអ៊ីអនម៉ល ភ្នំពេញ
មេសា ចាប់ផ្តើមផ្តល់កាតអ៊ីអន ពណ៌មាស
កក្កដា ចាប់ផ្តើមផ្តល់កាតអ៊ីអន ពណ៌ស្វាយ

## ២០១៧



មករា បើកសម្ពោធសាខាពោធិ៍ចិនតុង
កក្កដា ទីស្នាក់ការកណ្តាល និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តបាត់ដំបង
សីហា កែលំអការិយាល័យកណ្តាល
តុលា កែលំអ និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តសៀមរាប
ធ្នូ ទទួលបានពានរង្វាន់ពី VISA

## ២០១៨



មេសា ដាក់អោយដំណើរការ អ៊ីអនវ៉លឡេត
មេសា ចាប់ផ្តើមបង់រំលស់រថយន្ត
មិថុនា បើកសម្ពោធសាខា អ៊ីអន សែនសុខ
សីហា បើកសម្ពោធសាខាខេត្តតាកែវ
សីហា បើកសម្ពោធសាខាខេត្តបន្ទាយមានជ័យ
ធ្នូ ដាក់អោយដំណើរការ អ៊ីអនកាតម៉ូបាល (Scan to Pay)

## ២០១៩



មេសា ផ្លាស់ប្តូរអាសយដ្ឋានការិយាល័យកណ្តាល
មិថុនា កែលម្អ សាខាខេត្តបន្ទាយមានជ័យ
កក្កដា ប្តូរទីតាំង និងប្តូរឈ្មោះពី សាខាសុវណ្ណា ទៅជាសាខាស្ទឹងមានជ័យ
សីហា កែលម្អ និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តតាកែវ
វិច្ឆិកា បើកសម្ពោធសាខាច្បារអំពៅ

## ២០២០



ឧសភា ការកែលម្អ សាខាពោធិ៍ចិនតុង
សីហា ការកែលម្អ សាខាបាត់ដំបង
ធ្នូ ទទួលបានពានរង្វាន់ពី VISA

## ២០២១






ឧសភា ការកែលម្អ កន្លែងសម្រាក អ៊ីអនឡោញ សែនសុខ
សីហា ដាក់អោយដំណើរការ អូឡាំពិចកាតហ្វេស

## ២០២២








មករា ដាក់អោយដំណើរការ អ៊ីអនរហ័ស
ឧសភា ការកែលំអកន្លែងសម្រាក អ៊ីអនឡោញ ភ្នំពេញ
តុលា ដាក់អោយដំណើរការ FIFA កាតហ្វេស
ធ្នូ ទទួលបានពានរង្វាន់ពី VISA ២០២១ & ២០២២

# សមិទ្ធិផលឆ្នាំ២០២២




## សមិទ្ធិផល ឧបសគ្គ និងការគំរាមកំហែងពីមុន ៗ

### សមិទ្ធិផល

### ១ ការពង្រីកបន្ថែមនូវដៃគូសហការ / ដៃគូអាជីវកម្ម

១.១. យើងបានបង្កើនទំនាក់ទំនងជាមួយហាងដែលជាដៃគូសហការថ្មីចំនួន ២៧៤ បន្ថែមទៀតនៅក្នុងឆ្នាំ ២០២២ ប៉ុន្តែបានបិទការសហការជាមួយដៃគូចំនួន២៩៩ ដែលធ្វើឱ្យដៃគូសរុបកើនដល់ ៣.៦៧៩។ ចំនួនដៃគូសហការសរុបមានស្ថិរភាព ស្របពេលដែលដៃគូសហការខ្លះទៀតបានបិទអាជីវកម្មរបស់ខ្លួនដោយសារផលប៉ះពាល់នៃជម្ងឺកូវីដ១៩ ដែលបានអូសបន្លាយដល់ឆ្នាំ ២០២២។

១.២ យើងបានបង្កើត និងបន្តអាជីវកម្មជាមួយម៉ាកយីហោដែលជាដៃគូសហការ ចំនួន ១១៧ម៉ាក ដែលក្នុងនោះមានចំនួនហាង ១២៩កន្លែង ក្នុងឆ្នាំ២០២២។ សរុបជាលទ្ធផលរួមទាំងអស់ យើងទទួលបានយីហោដៃគូសហការរហូតដល់ទៅ ៨៩៥ម៉ាក និងចំនួនហាង ១.២០៦ កន្លែង។

១.៣. បង្កើត និងបន្តទំនាក់ទំនងអាជីវកម្មជាមួយនឹងហាងដែលប្រើប្រាស់អ៊ីអនកាតម៉ូបាលមានចំនួន ១៦១ ម៉ាក និងហាងចំនួន ១៧៩ កន្លែងក្នុងឆ្នាំ ២០២២។ ដែលសរុបទាំងអស់មានចំនួនម៉ាកយីហោរហូតដល់ទៅ ១.២៦៣ ម៉ាក និងហាងចំនួន ១.៤៩៦ កន្លែង។

១.៤. បង្កើនទំនាក់ទំនងអាជីវកម្មជាមួយហាងដែលប្រើប្រាស់អ៊ីអ៊ីនអនឡាញ ដែលមានចំនួនសរុបទាំងអស់គិតត្រឹមឆ្នាំ ២០២២ មានចំនួន ៦៧៤ ហាង ទាំងនៅផ្សារទំនើបអ៊ីអនម៉លភ្នំពេញ និងផ្សារអ៊ីអនម៉លសែនសុខស៊ីធី និងហាងខាងក្រៅផ្សេងទៀត។

### ២ ការពង្រឹងការបំពេញសេវាកម្មជូនអតិថិជន

២.១. ដើម្បីបម្រើអតិថិជនរបស់យើងឱ្យកាន់តែប្រសើរឡើង យើងបានពង្រឹង និងអភិវឌ្ឍបន្ថែមនូវសមត្ថភាពនៃផ្នែកបម្រើសេវាកម្មជូនអតិថិជន (Call Center) ឲ្យមានភាពរឹងមាំ ដែលអាចអនុញ្ញាតឲ្យភ្នាក់ងាររបស់យើង អាចឆ្លើយតបទៅនឹងការហៅចូលរបស់អតិថិជនបានទាន់ពេលវេលា។

២.២. ក្រៅពីប្រព័ន្ធនេះ យើងបានពង្រីកបណ្តាញហៅចូលកាន់តែច្រើនសម្រាប់អតិថិជនរបស់យើង ដើម្បីអាចទទួលបាននូវមតិយោបល់ ឬសំណើ ដែលរួមមានដូចជា ហ្វេសប៊ុក គេហទំព័រ ការទទួលសំណើតាមសាខាតាមរយៈប្រអប់ផ្តល់មតិយោបល់។ ព័ត៌មានបន្ថែមស្តីពីបណ្តាញទាំងនេះ អាចរកបាន និងបានបង្ហាញនៅលើគេហទំព័ររបស់យើងផ្ទាល់។

### ៣ ឥណទានបុគ្គល និងការបង់រំលស់បានថយចុះធៀបនឹងឆ្នាំ ២០២០

យើងបន្តប្រឈមមុខនឹងផលវិបាកពីការរាតត្បាតនៃជម្ងឺកូវីដ១៩ រហូតដល់ឆ្នាំ ២០២២ ខណៈដែលយើងបានដាក់ចេញនូវវិធានការរឹតបន្តឹងដើម្បីទប់ទល់ចំពោះផលប៉ះពាល់នៃជម្ងឺកូវីដ១៩ រហូតដល់ចុងខែឧសភា ឆ្នាំ២០២២ ហើយត្រូវបានបន្ធូរបន្ថយមកវិញនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ ២០២២ យើងនៅតែបន្តផ្តល់កម្ចីដល់អតិថិជនគោលដៅរបស់យើង ដើម្បីឲ្យស្របជាមួយនឹងគោលការណ៍អាជីវកម្មរបស់យើង។

៣.១. ដោយផ្តោតលើការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ និងសកម្មភាពផ្សេងៗតាមប្រព័ន្ធឌីជីថល (digital) យើងទទួលបានការលក់លើកម្ចីសាច់ប្រាក់បានចំនួនជាង ១៩,៣ លានដុល្លារអាមេរិក ស្មើនឹង ៩៤,៦ភាគរយ បើធៀបនឹងឆ្នាំមុន។ ក្នុងឆ្នាំ ២០២២ កម្ចីសាច់ប្រាក់ នៅតែជាផលិតផលសំខាន់ ដើម្បីរក្សាតុល្យភាពកម្ចីប្រាក់រៀល ដើម្បីបំពេញតាមតម្រូវការបទប្បញ្ញត្តិក្នុងអត្រា ១២,៩%។

៣.២. ប្រាក់កម្ចីដែលមានគោលបំណងជាក់លាក់ សម្រេចបានជាង ១៨,៦លានដុល្លារអាមេរិក ស្មើនឹង ៩៦,៧ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ យើងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូសហការសំខាន់ដូចជា ក្រុមហ៊ុនអេឡិចត្រូណិច ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ និងគ្រឿងសង្ហារឹម។

៣.៣. ប្រាក់កម្ចីលើការបង់រំលស់ម៉ូតូទទួលបានលទ្ធផល ១៣,៦ លានដុល្លារអាមេរិក ស្មើនឹង ៦២,៩ ភាគរយ បើធៀបនឹងឆ្នាំមុន។ ក្នុងឆ្នាំ ២០២២ យើងបន្តពង្រឹងគុណភាពប្រាក់កម្ចីរបស់យើង ខណៈដែលវិធានការទប់ទល់នឹងផលប៉ះពាល់ពីជម្ងឺកូវីដ ១៩ ត្រូវបានរក្សារហូតដល់បានដកចេញទាំងស្រុងនៅក្នុង ខែកញ្ញា ឆ្នាំ ២០២២។ ជាលទ្ធផលប្រាក់កម្ចីម៉ូតូ បានចាប់ផ្តើមងើបឡើងវិញ និងបន្តប្រសើរឡើង។

៣.៤. ប្រាក់កម្ចីលើការបង់រំលស់រថយន្តសម្រេចបាន១៣,៤ លានដុល្លារ ដែលស្មើនឹង ៦៩ ភាគរយ បើធៀបនឹងឆ្នាំមុន។ ប្រាក់កម្ចីរថយន្តរបស់យើង នៅតែបន្តរងផលប៉ះពាល់ពីជម្ងឺកូវីដ១៩ និងស្ថិតនៅក្រោមការរឹតបន្តឹងដែលជាវិធានទប់ទល់របស់យើង។ ហេតុដូច្នេះហើយ ទើបការលក់បានធ្លាក់ចុះក្នុងឆមាសទីមួយ។ ទោះយ៉ាងណាក៏ដោយ ផលិតផលនេះ បានចាប់ផ្តើមងើបឡើងវិញនៅឆមាសទីពីរនៃឆ្នាំសារពើពន្ធ ដោយសារការដកចេញនូវការរឹតបន្តឹង។

# សង្ខេបព័ត៌មានអាជីវកម្មសំខាន់ៗឆ្នាំ២០២២

## សកម្មភាពឆ្នាំ ២០២២

អំឡុងពេលនៃការរាតត្បាតនៃជម្ងឺ កូវីដ១៩ ឥរិយាបទរបស់អតិថិជនបានផ្លាស់ប្តូរ ហើយវាត្រូវបានគេកត់សម្គាល់ថាបានឈានទៅរកផ្នត់គំនិតបែបឌីជីថល។ ក្នុងឆ្នាំ២០២២ យើងបានដាក់អោយប្រើប្រាស់នូវ កម្មវិធី "AEON Rohas" ដែលជាកម្មវិធីទូរស័ព្ទឌីជីថល សម្រាប់គាំទ្រអតិថិជនរបស់យើងក្នុងការស្នើសុំ កម្ចីជាសាច់ប្រាក់ នៅគ្រប់ទីកន្លែងគ្រប់ពេលវេលា។

ទន្ទឹមនឹងនេះ យើងបានចាប់ផ្តើមគម្រោងអាជីវកម្ម Prepaid ជាមួយ VISA ដើម្បីពង្រីកមូលដ្ឋានអតិថិជនរបស់ក្រុមហ៊ុនយើង និងបង្កើតប្រព័ន្ធអេកូឡូស៊ី AEON នាពេលខាងមុខ។

## ផែនការ និងការអនុវត្តអាទិភាពសម្រាប់ឆ្នាំ ២០២៣

មានរបស់ខ្លះ បានបាត់ដោយសារផលប៉ះពាល់នៃជម្ងឺកូវីដ១៩ របស់ខ្លះទើបនឹងលេចរូបរាងឡើងថ្មី ហើយរបស់ខ្លះទៀតគឺនៅដដែល បើទោះក្រោយមានជម្ងឺកូវីដ១៩។ ការទូទាត់តាមទូរស័ព្ទ និងឌីជីថល បានក្លាយជាការពេញនិយមសម្រាប់ការទូទាត់ខ្នាតតូច និងមធ្យមហើយវាបានកើនឡើងកាន់តែច្រើនលើប្រតិបត្តិការដោយគ្មានសាច់ប្រាក់។ អាជីវកម្មPrepaid ជាមួយ VISA និងកម្មវិធីទូរស័ព្ទ ដែលមានមុខងារជាច្រើននឹងត្រូវបានណែនាំទៅកាន់ទីផ្សារ ដែលវាមានលក្ខណៈប្រសើរលើសពីការទូទាត់ប្រាក់ទៅទៀត។ នៅឆ្នាំ ២០២៣ យើងនឹងបន្តធ្វើឱ្យប្រសើរឡើងនូវកម្មវិធីទូរស័ព្ទ AEON Rohas ដំណាក់កាលទី ២ ដោយរួមបញ្ចូលការវិនិច្ឆ័យដោយស្វ័យប្រវត្តិ ដើម្បីបង្កើនល្បឿនវិនិច្ឆ័យ និងបំពេញចិត្តអតិថិជនតាមរយៈវេទិកាឌីជីថលរបស់យើង។ លើសពីនេះ យើងនឹងបន្តពង្រឹងផលិតផលដែលមានស្រាប់របស់យើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន ក៏ដូចជាការពង្រីកផ្នែកទីផ្សារផងដែរ។

យើងបន្តគាំទ្រក្នុងការដោះស្រាយបញ្ហាសង្គមតាមតំបន់ដូចជា ការសម្រេចឲ្យបាននូវសង្គមប្រកបដោយនិរន្តរភាព បរិយាប័ន្នផ្នែកហិរញ្ញវត្ថុ ក៏ដូចជាបរិយាប័ន្នផ្នែកហិរញ្ញវត្ថុឌីជីថល ស្របពេលដែលយើងបន្តការប្តេជ្ញាចិត្តរបស់យើងក្នុងការផ្តល់នូវផលិតផល និងសេវាកម្មស្របតាម "របៀបរស់នៅថ្មី" ដោយធ្វើតាមទស្សនៈរបស់យើង "សាមញ្ញ រហ័ស ងាយស្រួល"។



# ទស្សនវិស័យអាជីវកម្មឆ្នាំ២០២៣




## ប័ណ្ណឥណទាន

ក្រុមហ៊ុនយើង នៅតែឈរក្នុងលំដាប់លេខ១ និងបានកាន់កាប់រហូតដល់ ៣៧% នៃចំនួនប័ណ្ណឥណទានសរុបដែលបានចេញនៅក្នុងប្រទេសកម្ពុជា (យោងតាមរបាយការណ៍របស់ VISA ក្នុងត្រីមាសទី៤ ឆ្នាំ ២០២២)។ យើងមាន កាតដែលមានសុពលភាពសរុបចំនួន ៤៦.៨៥៨ កាតគិតត្រឹមខែធ្នូ ឆ្នាំ២០២២ និងឈរក្នុងលំដាប់លេខ៣ ចំពោះការទូទាត់ និងបានកាន់កាប់រហូតដល់ ១៥% នៅក្នុងទីផ្សារ (យោងតាមរបាយការណ៍របស់ VISA ក្នុងត្រីមាសទី៤ ឆ្នាំ ២០២២)។

សូមអរគុណដល់អតិថិជនដែលជាម្ចាស់អ៊ីអនកាត ដៃគូសហការ និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងអស់របស់ក្រុមហ៊ុន សម្រាប់ការខិតខំប្រឹងប្រែង និងធ្វើអោយសមិទ្ធិផលមួយនេះសម្រេចទៅបានដោយជោគជ័យ។

ក្រុមហ៊ុនយើងនៅតែបន្ត និងធ្វើការពង្រឹងបន្ថែមនូវកម្មវិធីសន្សំពិន្ទុ "Happy Plus Point" ដែលផ្តល់ជូនអតិថិជននូវជម្រើសជាច្រើនសម្រាប់ការប្តូរពិន្ទុដូចជា៖ សន្លឹកប័ណ្ណទូទាត់ជាទឹកប្រាក់ វត្ថុអនុស្សាវរីយ៍ និងការបញ្ចូលទឹកប្រាក់ទៅក្នុងអ៊ីអនកាតរបស់អតិថិជនផ្ទាល់ ដើម្បីផ្តល់ជាអត្ថប្រយោជន៍ពីការប្រើប្រាស់របស់ពួកគេ។ យើងបានធ្វើការផ្សព្វផ្សាយជាច្រើនដើម្បីរក្សានៅការប្រើប្រាស់ពីអតិថិជន ជាមួយដៃគូសហការ ដូចជាការចាក់សាំងបានប្រាក់ត្រឡប់មកវិញ ញ៉ាំមួយថែមមួយ ធ្វើការកម្មង់អាហារ បញ្ជាទិញទំនិញពីក្រៅប្រទេស និងប្រម៉ូសិនផ្សេងៗជាច្រើនទៀត។

អតិថិជនអ៊ីអនកាតរបស់ក្រុមហ៊ុនយើង នឹងទទួលបាននូវការផ្តល់នូវអត្ថប្រយោជន៍បន្ថែម ដោយទទួលបាននូវការបញ្ចុះតម្លៃរហូតដល់ ៥០% ជាមួយដៃគូសហការជាង ១.២០៦ ហាង។ យើងបានបន្តពង្រីកបន្ថែមដៃគូសហការ និងជួយគាំទ្រដល់អាជីវកម្មខ្នាតតូច ដើម្បីរក្សានៅការទូទាត់ដោយមិនប្រើប្រាស់ក្រដាសប្រាក់បន្ថែមចំនួន១.២៦៣ ម៉ាក និង ១.៤៩៦ ហាង ត្រឹមខែធ្នូ ឆ្នាំ ២០២២ (ដៃគូសហការដែលឈរនៅចំណាត់ថ្នាក់កំពូលគឺ ផ្នែកអាហារ និងភេសជ្ជៈមាន ៦២% សម្លៀកបំពាក់ និងគ្រឿងតុបតែងខ្លួនមាន ២៤% ការថែទាំសុខភាពមាន ៥% និង៩% សម្រាប់ប្រភេទផ្សេងៗទៀត)។ ដៃគូសហការភាគច្រើនគឺជាអាជីវកម្មខ្នាតតូច ដូច្នេះការទូទាត់មានទំហំទឹកប្រាក់តិចតួច ដែលធ្វើឲ្យយើងអាចបង្កើនការទូទាត់តាមទូរស័ព្ទដៃ និងកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់នៅក្នុងទីផ្សារ។

ក្រុមហ៊ុនយើង នឹងបន្តធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាព/មុខងារ ផលិតផលរបស់យើង ដើម្បីផ្តល់ជូននូវសេវាកម្មល្អបំផុត ជូនចំពោះអតិថិជនដែលជាម្ចាស់ អ៊ីអនកាត ហើយការផ្តល់ជូននេះ មិនចំពោះតែអតិថិជនដែលជាម្ចាស់អ៊ីអនកាត ប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជូនចំពោះអតិថិជន អ៊ីអនកាតម៉ូបាលផងដែរ ដើម្បីធ្វើឲ្យអតិថិជនទទួលបាននូវភាពងាយស្រួលក្នុងការចុះឈ្មោះប្រើប្រាស់ សុវត្ថិភាពក្នុងការប្រើប្រាស់កាត ការគ្រប់គ្រងកាត បើកដំណើរការកាត បិទដំណើរការកាត ការពិនិត្យមើលសមតុល្យឥណទាន ពិនិត្យមើលប្រតិបត្តិការ របាយការណ៍វិក្កយបត្រប្រចាំខែ និងពិនិត្យមើលពិន្ទុសន្សំដែលលោកអ្នកទទួលបានជាដើម។ មិនត្រឹមតែប៉ុណ្ណោះការទូទាត់បានយ៉ាងឆាប់រហ័សតាមរយៈការ "ស្កេនដើម្បីទូទាត់" ដោយគ្រាន់តែស្កេន QR កូដ ពីទូរស័ព្ទស្មាតហ្វូនរបស់អតិថិជនដោយផ្ទាល់។ លើសពីនេះទៅទៀតមុខងារ Contactless ក៏អនុញ្ញាតឲ្យអតិថិជនធ្វើការទូទាត់បានយ៉ាងរហ័សដោយគ្រាន់តែ "ប៉ះដើម្បី ទូទាត់"។

## កម្ចីសាច់ប្រាក់ជាប្រាក់រៀល




ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ប្រាក់រៀល យើងបន្តផ្តោតទៅលើការធ្វើអោយប្រសើរឡើងនូវកម្ចីប្រាក់រៀលឲ្យស្របតាមលក្ខខណ្ឌរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងឆ្នាំ ២០២២ កម្ចីជាប្រាក់រៀលមានចំនួន១២,៩០% នៃផលប័ត្រសរុប ខណៈពេលដែលកម្ចីជាសាច់ប្រាក់នៅតែជាផលិតផលសំខាន់របស់យើងក្នុងការជំរុញកម្ចីប្រាក់រៀល បើទោះបីជាយើងដាក់ឲ្យដំណើរការនូវកម្ចីប្រាក់រៀលសម្រាប់សេវាកម្មបង់រំលស់ក៏ដោយ។ នៅឆ្នាំ ២០២៣ យើងនៅតែបន្តលើកកម្ពស់ និងគាំទ្រកម្ចីប្រាក់រៀលរបស់យើង ដើម្បីបំពេញតាមតម្រូវការបទប្បញ្ញត្តិ ក៏ដូចជាការលើកកម្ពស់ប្រាក់រៀលខ្មែរនៅលើទីផ្សារ។

# ការត្រួតពិនិត្យផ្ទៃក្នុង



## ការប្រតិបត្តិតាមរបស់ធនាគារ

ការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព បង្ហាញពីភាពរឹងមាំ និងសុវត្ថិភាពរបស់ដំណើរការធនាគារ។ ការរៀបចំដ៏សមស្រប និងការពង្រឹងប្រព័ន្ធប្រតិបត្តិការ និងការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយសង្គតិភាព ជួយឲ្យក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនរក្សាបាននូវធនធាន ចេញនូវរបាយការណ៍ហិរញ្ញវត្ថុដ៏គួរឲ្យទុកចិត្ត និងប្រតិបត្តិតាមនូវរាល់ច្បាប់ និងបទបញ្ញត្តិផ្សេងៗ។ ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង ក៏ជួយកាត់បន្ថយនូវឱកាសនៃការកើតឡើងនូវបញ្ហាសំខាន់ៗ និងភាពមិនប្រក្រតី មួយចំនួនព្រមទាំងជួយក្នុងការទប់ស្កាត់នូវបញ្ហាទាំងនោះទាន់ពេលវេលា នៅពេលដែលវាបានកើតឡើង។ ក្នុងនោះដែរ មុខងារប្រតិបត្តិតាម ពិតជាចូលរួមចំណែក និងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងសកម្មភាពនៃការត្រួតពិនិត្យផ្ទៃក្នុងជាលក្ខណៈអចិន្ត្រៃយ៍របស់ក្រុមហ៊ុន។ ក្នុងនាមជាអ្នកការពារនៅស្រទាប់ទី២ ដោយផ្តាច់ចេញពីមុខងារការត្រួតពិនិត្យផ្ទៃក្នុងដទៃទៀតរបស់ក្រុមហ៊ុន មុខងារប្រតិបត្តិតាម គឺជាមុខងារដែលឯករាជ្យ ដែលមិនពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ដើម្បីបញ្ចៀសពីទំនាស់នៃផលប្រយោជន៍។ តួនាទីដ៏សំខាន់របស់មុខងារប្រតិបត្តិតាម គឺដើម្បីធានាឲ្យបានថា ប្រតិបត្តិការរចនាសម្ព័ន្ធ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អនុលោមតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធ ក្រមសីលធម៌ ទម្លាប់នៃការអនុវត្តប្រតិបត្តិការ និងយុទ្ធសាស្ត្រអាជីវកម្ម ដែលត្រូវបានកំណត់ដោយគណៈប្រតិបត្តិ។ នៅក្នុងឆ្នាំ ២០២២ ផ្នែកប្រតិបត្តិតាម បានធ្វើបច្ចុប្បន្នភាពទៅលើគោលនយោបាយ បទបញ្ញត្តិ និងនីតិវិធី ដែលទាក់ទងទៅនឹងក្របខណ្ឌប្រតិបត្តិតាម និងទៅលើគោលនយោបាយ បទបញ្ញត្តិ និងនីតិវិធីដទៃទៀត ដើម្បីឲ្យមានភាពសមស្របទៅនឹងការរីកចម្រើននៃផលិតផល សេវាកម្ម និន្នាកាទីផ្សារ និងជាពិសេស ឲ្យស្របទៅនឹងច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ឯកសារ និងសម្ភារៈដែលប្រើប្រាស់ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលក៏ត្រូវបានធ្វើការកែប្រែ និងថែមទាំងបានផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិករបស់យើង ដើម្បីធានាថា ចំណេះដឹង និងការយល់ដឹងរបស់ពួកគេ បានឆ្លើយតបទៅនឹងការកាត់បន្ថយហានិភ័យនៃការមិនប្រតិបត្តិតាម ហានិភ័យផ្នែកច្បាប់ និងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ នៅឆ្នាំ ២០២៣ យើងបានរៀបចំផែនការក្នុងការបង្កើតឲ្យមាននូវកម្មវិធីរៀបចំប្រព័ន្ធប្រតិបត្តិតាម ដែលរួមមានការធ្វើបច្ចុប្បន្នភាពលើរាល់គោលនយោបាយ បទបញ្ញត្តិ និងនីតិវិធី ដែលពាក់ព័ន្ធបង្កើតឲ្យមាននូវបញ្ជីតាមដានការប្រតិបត្តិតាម និងកំណត់ពីផែនការក្នុងការតាមដាន និងត្រួតពិនិត្យបង្កើតអោយមានកម្មវិធីសមស្របក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងយន្តការនៃការរាយការណ៍ ដើម្បីពង្រឹងមុខាងប្រតិបត្តិតាម ក្នុងការជួយឲ្យក្រុមហ៊ុនគ្រប់គ្រងការត្រួតពិនិត្យផ្ទៃក្នុងឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។




## ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនចាត់ទុកការគ្រប់គ្រងហានិភ័យ ជាធាតុសំខាន់មួយនៃអាជីវកម្ម និងបង្កប់វប្បធម៌ហានិភ័យរឹងមាំ នៅក្នុងប្រតិបត្តិការអាជីវកម្ម ពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយយល់ច្បាស់អំពីសារៈសំខាន់នៃការគ្រប់គ្រងហានិភ័យ ដើម្បីឲ្យមានការរីកចម្រើនប្រកបដោយចីរភាព ក្រុមការងារគ្រប់គ្រងហានិភ័យបានចូលរួមក្នុងដំណាក់កាលដំណើរការគ្រប់គ្រងហានិភ័យ ដើម្បីផ្តល់នូវគំនិត និងទស្សនៈដោយឯករាជ្យ ដូចជាកាត្រួតពិនិត្យ ការរៀបចំផែនការ និងការដឹកនាំការគ្រប់គ្រងហានិភ័យរបស់ខ្លួនផ្ទាល់។ ក្រុមហ៊ុនបានរៀបចំអោយមាននូវកិច្ចប្រជុំការគ្រប់គ្រងហានិភ័យថ្នាក់តំបន់ប្រចាំខែ ដែលមានសមាសភាពចូលរួម ពីប្រទេសជប៉ុន ថៃ ភូមា និងឡាវ ដែលសុទ្ធសឹងជាក្រុមហ៊ុនសម្ព័ន្ធ នៃអ៊ីអនគ្រុប។

# ទំនួលខុសត្រូវ ផ្នែកសង្គមរបស់ក្រុមហ៊ុន





### ចំណុចឆ្លុះបញ្ចាំងសម្រាប់ឆ្នាំ ២០២២

ឆ្នាំ ២០២២ យើងនៅតែបន្តផ្តល់អាហារូបករណ៍អ៊ីអន ១ ភាគរយ។ ចំណែកឯសកម្មភាពសម្អាតទីក្រុងត្រូវបានផ្អាក។

### ផែនការសំខាន់សម្រាប់ឆ្នាំ ២០២៣

យើងនឹងពិចារណាក្នុងការបន្តសកម្មភាពសម្អាតទីក្រុងឡើងវិញ។ យើងគ្រោងនឹងបន្តបរិច្ចាគទៅដល់កាកបាទក្រហមកម្ពុជា និងវត្តអារាមនានាដែលយើងបាន និងកំពុងបរិច្ចាគជាបន្តបន្ទាប់។ យើងនឹងចូលរួមយ៉ាងសកម្មក្នុងការឧបត្ថម្ភផងដែរ។

| | |
|---|---|
| ឧសភា | បរិច្ចាគទៅកាន់កាកបាទក្រហមកម្ពុជាសាខាខេត្តបាត់ដំបង និងតាកែវ |
| ឧសភា | ឧបត្ថម្ភកម្មវិធីអ្នកបន្តវេនរបស់វិទ្យាស្ថានស៊ីអ៊ីអូ / ស៊ីអ៊ីអូម៉ាស្ទ័រក្លឹប |
| កក្កដា | បរិច្ចាគទៅកាន់សមាគមធនាគារនៅកម្ពុជាសម្រាប់ការបោះពុម្ពសៀវភៅចំណេះដឹងហិរញ្ញវត្ថុ |
| តុលា | ចូលរួមកម្មវិធីដាំកូនឈើនៅផ្សារទំនើបអ៊ីអនមានជ័យក្នុងនាមសមាជិកអ៊ីអនគ្រុប |
| តុលា | បរិច្ចាគទៅកាន់សមាគមធនាគារនៅកម្ពុជាសម្រាប់ជំនួយគ្រោះទឹកជំនន់ |
| ធ្នូ | ផ្តល់អាហារូបករណ៍ក្លឹបអ៊ីអន ១% ដល់ "សាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ" |



តួលេខចាប់ពីទំព័រ ១៧ ដល់ ៤០ ត្រូវបានដកស្រង់ចេញពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលក្នុងនោះសវនករ ក្រុមហ៊ុន Deloitte (Cambodia) Co., Ltd., បង្ហាញទស្សនៈពិត និងយុត្តិធម៌ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

*នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២*

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៨២៧.៩៧៨ | ៣.៤០៨.៧៨៥ | ១.០៥៦.២៥៦ | ៤.៣០៣.១៨៧ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៦.២០១.១៧៨ | ២៥.៥៣០.២៥០ | ៥.៦៤៤.៨៥២ | ២២.៩៩៧.១២៧ |
| សមតុល្យនៅធនាគារផ្សេងៗ | ៥.៩៨១.៣១៣ | ២៤.៦២៥.០៦៦ | ៣.៨៤៦.៩០១ | ១៥.៦៧២.២៧៥ |
| ឥណទានផ្តល់ដល់អតិថិជន | ១២០.៤៩០.១២៧ | ៤៩៦.០៥៧.៨៥៣ | ១២៦.៧៨៣.៤៩៨ | ៥១៦.៥១៥.៩៧១ |
| ទ្រព្យសកម្មផ្សេងៗ | ៣.២២៤.៤៦៨ | ១៣.២៧៥.១៣៥ | ២.៥៣៩.៨៩៧ | ១០.៣៤៧.៥៤០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១.៣៨៩.៨៨០ | ៥.៧២២.១៣៦ | ១.២៨៤.៥៧២ | ៥.២៣៣.៣៤៦ |
| ទ្រព្យសកម្មអរូបី | ១.៩៨៤.២២៦ | ៨.១៦៩.០៥៨ | ១.៩៦០.៨០៧ | ៧.៩៨៨.៣២៨ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ១.៩៧៩.៤៧២ | ៨.១៤៩.៤៨៦ | ១.៦១៣.៩១៣ | ៦.៥៧៥.០៨២ |
| ទ្រព្យសកម្មពន្ធពន្យារ | ១.៨៤០.១៩៤ | ៧.៥៧៦.០៧៩ | ២.៩២០.០៤១ | ១១.៨៩៦.២៤៧ |
| **ទ្រព្យសកម្មសរុប** | ១៤៣.៩១៨.៨៣៦ | ៥៩២.៥១៣.៨៤៨ | ១៤៧.៦៥០.៧៣៧ | ៦០១.៥២៩.១០៣ |
| **បំណុល** | | | | |
| បំណុលពន្ធចរន្ត | ៥១១.៦៤០ | ២.១០៦.៤២២ | ៣៤៣.១៣៩ | ១.៣៩៧.៩៤៨ |
| បំណុលផ្សេងៗ | ៣.៥២៨.៨៦៧ | ១៤.៥២៨.៣៤៥ | ២.៩០៩.៣៥១ | ១១.៨៥២.៦៩៦ |
| សំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ | ៣៥៦.៣៥០ | ១.៤៦៧.០៩៣ | ៣៣៥.៨៩៤ | ១.៣៦៨.៤៣២ |
| ប្រាក់កម្ចី | ៩៦.៣៤៨.២២៣ | ៣៩៦.៦៦៥.៦៣៤ | ១០៧.៦៦៦.៥៤០ | ៤៣៨.៦៣៣.៤៨៤ |
| អនុបំណុល | ៧.៣២៦.៧០៧ | ៣០.១៦៤.០៥៣ | ៨.១២៥.៨៩៤ | ៣៣.១០៤.៨៩២ |
| បំណុលភតិសន្យា | ១.៩០៤.១៩៥ | ៧.៨៣៩.៥៧១ | ១.៥៦៧.៣០៦ | ៦.៣៨៥.២០៥ |
| កាតព្វកិច្ចលើអត្ថប្រយោជន៍បុគ្គលិក | ១០២.៥១៩ | ៤២២.០៧១ | ១៣៦.៤៩៥ | ៥៥៦.០៨១ |
| **បំណុលសរុប** | ១១០.០៧៨.៥០១ | ៤៥៣.១៩៣.១៨៩ | ១២១.០៨៤.៦១៩ | ៤៩៣.២៩៨.៧៣៨ |
| **មូលធន** | | | | |
| ដើមទុន | ២០.០០០.០០០ | ៨២.៣៤០.០០០ | ២០.០០០.០០០ | ៨១.៤៨០.០០០ |
| ប្រាក់ចំណេញរក្សាទុក | ១៣.៨៤០.៣៣៥ | ៥៦.៣៨៩.៥៨៤ | ៦.៥៦៦.១១៨ | ២៦.៦៥៩.៨៥៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥៩១.០៧៥ | - | ៩០.៥០៧ |
| **មូលធនសរុប** | ៣៣.៨៤០.៣៣៥ | ១៣៩.៣២០.៦៥៩ | ២៦.៥៦៦.១១៨ | ១០៨.២៣០.៣៦៥ |
| **បំណុល និងមូលធនសរុប** | ១៤៣.៩១៨.៨៣៦ | ៥៩២.៥១៣.៨៤៨ | ១៤៧.៦៥០.៧៣៧ | ៦០១.៥២៩.១០៣ |

# របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២៩.៩១៩.៣៧៩ | ១២២.២៨០.៥០២ | ៣៣.១៨៦.៨៦៥ | ១៣៥.០០៤.១៦៧ |
| ចំណាយការប្រាក់ | (៤.០១៦.០៩៤) | (១៦.៤១៣.៧៧៦) | (៤.០១៤.៥២០) | (១៦.៣៣១.០៦៧) |
| **ចំណូលសុទ្ធពីការប្រាក់** | ២៥.៩០៣.២៨៥ | ១០៥.៨៦៦.៧២៦ | ២៩.១៧២.៣៤៥ | ១១៨.៦៧៣.១០០ |
| ចំណូលពីថ្លៃឈ្នួលកម្រៃជើងសារ | ២.២១០.៦២៩ | ៩.០៣៤.៨៤១ | ២.១៧៨.៩២១ | ៨.៨៦៣.៨៥១ |
| ចំណូលផ្សេងៗសុទ្ធ | ១.៦១៦.៤៣៥ | ៦.៦០៦.៣៧០ | ៥០០.២៣៥ | ២.០៣៤.៩៥៦ |
| **ចំណេញពីប្រតិបត្តិការ** | ២៩.៧៣០.៣៤៩ | ១២១.៥០៧.៩៣៧ | ៣១.៨៥១.៥០១ | ១២៩.៥៧១.៩០៧ |
| ចំណាយបុគ្គលិក | (៨.៦២៨.៨០៥) | (៣៥.២៦៥.៩២៦) | (៨.០៨៤.២៤២) | (៣២.៨៨៦.៦៩៧) |
| ចំណាយរំលស់ | (២.២០៥.៦៧៥) | (៩.០១៤.៥៩៤) | (២.២៤៧.៦០៤) | (៩.១៤៣.២៥៣) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៦.៣៧៤.៤១៦) | (២៦.០៥២.២៣៨) | (៥.៨៣០.១៤៤) | (២៣.៧១៧.០២៦) |
| ការខាតបង់លើឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ | (៣.៣៨២.៧៥៣) | (១៣.៨២៥.៣១២) | (១៤.៦៧៥.៨៦៨) | (៥៩.៧០១.៤៣១) |
| **ប្រាក់ចំណេញមុនដកពន្ធ** | ៩.១៣៨.៧០០ | ៣៧.៣៤៩.៨៦៧ | ១.០១៣.៦៤៣ | ៤.១២៣.៥០០ |
| ចំណាយពន្ធលើប្រាក់ចំណូល | (១.៨៦៤.៤៨៣) | (៧.៦២០.១៤២) | (៣០០.៣៥០) | (១.២២១.៨២៤) |
| ប្រាក់ចំណេញក្នុងឆ្នាំ | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ | ៧១៣.២៩៣ | ២.៩០១.៦៧៦ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥០០.៥៦៩ | - | ១៧៤.០១២ |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | ៧.២៧៤.២១៧ | ៣០.២៣០.២៩៤ | ៧១៣.២៩៣ | ៣.០៧៥.៦៨៨ |

# របាយការណ៍បម្រែបម្រួលមូលធន

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២*

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ២០.០០០.០០០ | ៨០.៩០០.០០០ | ៥.៨៥២.៨២៥ | ២៣.៧៥៨.១៨២ | (៨៣.៥០៥) | ២៥.៨៥២.៨២៥ | ១០៤.៥៧៤.៦៧៧ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ៧១៣.២៩៣ | ២.៩០១.៦៧៦ | - | ៧១៣.២៩៣ | ២.៩០១.៦៧៦ |
| លទ្ធផលលម្អិតផ្សេងៗ<br>- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ១៧៤.០១២ | - | ១៧៤.០១២ |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | - | - | ៧១៣.២៩៣ | ២.៩០១.៦៧៦ | ១៧៤.០១២ | ៧១៣.២៩៣ | ៣.០៧៥.៦៨៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥៨០.០០០ | - | - | - | - | ៥៨០.០០០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ២០.០០០.០០០ | ៨១.៤៨០.០០០ | ៦.៥៦៦.១១៨ | ២៦.៦៥៩.៨៥៨ | ៩០.៥០៧ | ២៦.៥៦៦.១១៨ | ១០៨.២៣០.៣៦៥ |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ២០.០០០.០០០ | ៨១.៤៨០.០០០ | ៦.៥៦៦.១១៨ | ២៦.៦៥៩.៨៥៨ | ៩០.៥០៧ | ២៦.៥៦៦.១១៨ | ១០៨.២៣០.៣៦៥ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ |
| លទ្ធផលលម្អិតផ្សេងៗ<br>- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ៥០០.៥៦៩ | - | ៥០០.៥៦៩ |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | - | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ | ៥០០.៥៦៩ | ៧.២៧៤.២១៧ | ៣០.២៣០.២៩៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៨៦០.០០០ | - | - | - | - | ៨៦០.០០០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ២០.០០០.០០០ | ៨២.៣៤០.០០០ | ១៣.៨៤០.៣៣៥ | ៥៦.៣៨៩.៥៨៣ | ៥៩១.០៧៦ | ៣៣.៨៤០.៣៣៥ | ១៣៩.៣២០.៦៥៩ |

# របាយការណ៍លំហូរសាច់ប្រាក់

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | ៩.១៣៨.៧០០ | ៣៧.៣៤៩.៨៦៧ | ១.០១៣.៦៤៣ | ៤.១២៣.៥០០ |
| *និយ័តកម្មលើ៖* | | | | |
| កាតព្វកិច្ចលើអត្ថប្រយោជន៍បុគ្គលិក | (៣៣.៩៧៦) | (១៣៨.៨៦០) | (១៩.២៩៧) | (៧៨.៥០០) |
| ចំណាយរំលស់ | ២.២០៥.៦៧៥ | ៩.០១៤.៥៩៤ | ២.២៤៧.៦០៤ | ៩.១៤៣.២៥៣ |
| ខាតបង់លើឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ | ៣.៣៨២.៧៥៣ | ១៣.៨២៥.៣១២ | ១៤.៦៧៥.៨៦៨ | ៥៩.៧០១.៤៣១ |
| ខាតបង់ពីការលក់ និងលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ | ៣៥០ | ១.៤៣០ | ១.៦០២ | ៦.៥១៧ |
| ខាតបង់ពីការលុបចោលទ្រព្យអរូបី | ២១.៥៦១ | ៨៨.១២០ | - | - |
| ចំណូលការប្រាក់ | (២៩.៩១៩.៣៧៩) | (១២២.២៨០.៥០២) | (៣៣.១៨៦.៨៦៥) | (១៣៥.០០៤.១៦៧) |
| ចំណាយការប្រាក់ | ៤.០១៦.០៩៤ | ១៦.៤១៣.៧៧៦ | ៤.០១៤.៥២០ | ១៦.៣៣១.០៦៧ |
| ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ | (២៦២.៥៨៣) | (១.០៨១.០៥៤) | (១០៤.៥៣១) | (៤២៥.៨៥៩) |
| | (១១.៤៥០.៨០៥) | (៤៦.៨០៧.៣១៧) | (១១.៣៥៧.៤៥៦) | (៤៦.២០២.៧៥៨) |
| *បម្រែបម្រួល៖* | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | (៥៥២.១០៧) | (២.២៥៦.៤៦១) | ១.៦៥៣.៩០៣ | ៦.៧២៨.០៧៧ |
| ឥណទានផ្តល់ដល់អតិថិជន | ២.៣៦២.០៣១ | ៩.៦៥៣.៦២១ | (៧.៧៩៤.៦៣៩) | (៣១.៧០៨.៥៩១) |
| ទ្រព្យសកម្មផ្សេងៗ | (៦៨៤.៥៧១) | (២.៧៩៧.៨៤២) | ៥១៦.៨៤៥ | ២.១០២.៥២៥ |
| បំណុលផ្សេងៗ | ៦២០.៣២៩ | ២.៥៣៥.២៨៥ | (១.១១៤.១១០) | (៤.៥៣២.១៩៩) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (៩.៧០៥.១២៣) | (៣៩.៦៧២.៧១៤) | (១៨.០៩៥.៤៥៧) | (៧៣.៦១២.៩៤៦) |
| ការប្រាក់បានទទួល | ៣០.៤៩២.៧០៨ | ១២៤.៦២៣.៦៩៨ | ៣២.៨៤៩.៨៣៣ | ១៣៣.៦៣៣.១២១ |
| ការប្រាក់បានបង់ | (៣.៨៥៧.៦១៩) | (១៥.៧៦៦.០៨៩) | (៣.៩២៥.៧២៤) | (១៥.៩៦៩.៨៤៥) |
| ពន្ធលើប្រាក់ចំណូលបានបង់ | (៦១៦.១៣៥) | (២.៥១៨.១៤៤) | (១.៦៩៦.៦៧៥) | (៦.៩០២.០៧៤) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | ១៦.៣១៣.៨៣១ | ៦៦.៦៦៦.៧៥១ | ៩.១៣១.៩៧៧ | ៣៧.១៤៨.២៥៦ |

# របាយការណ៍លំហូរសាច់ប្រាក់ (ត)

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (៨១០.០៨៤) | (៣.៣១០.៨១៣) | (៤១៩.៦០៦) | (១.៧០៦.៩៥៧) |
| ការទិញទ្រព្យសកម្មអរូបី | (៥២៧.៦៥៥) | (២.១៥៦.៥២៦) | (១៧៨.៣៦៦) | (៧២៥.៥៩៣) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១.០៣១ | ៤.២១៤ | ១៧៧ | ៧២០ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាព វិនិយោគ** | (១.៣៣៦.៧០៨) | (៥.៤៦៣.១២៥) | (៥៩៧.៧៩៥) | (២.៤៣១.៨៣០) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ២៤.៩០១.៦០៣ | ១០១.៧៧២.៨៥១ | ៤០.២៥៨.៣២១ | ១៦៣.៧៧០.៨៥០ |
| ការទូទាត់សងប្រាក់កម្ចី | (៣៦.១១៥.៨១២) | (១៤៧.៦០៥.៣២៤) | (៤៦.០២៩.២៥៨) | (១៨៧.២៤៧.០២២) |
| សាច់ប្រាក់បានពីអនុបំណុល | (៨០០.០០០) | (៣.២៦៩.៦០០) | - | - |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | (១.០៤៨.២៧៥) | (៤.២៨៤.៣០០) | (៩១៤.០៣៦) | (៣.៧១៨.២៩៨) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | (១៣.០៦២.៤៨៤) | (៥៣.៣៨៦.៣៧៣) | (៦.៦៨៤.៩៧៣) | (២៧.១៩៤.៤៧០) |
| ការកើនឡើងនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១.៩១៤.៦៣៩ | ៧.៨១៧.២៥៣ | ១.៨៤៩.២០៩ | ៧.៥២១.៩៥៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមឆ្នាំ | ៤.៩៦០.២៥៥ | ២០.២០៨.០៨០ | ៣.១១១.០៤៦ | ១២.៥៨៤.១៨១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ២៧៨.៦០៥ | - | ១០១.៩៤៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៦.៨៧៤.៨៩៤ | ២៨.៣០៣.៩៣៨ | ៤.៩៦០.២៥៥ | ២០.២០៨.០៨០ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២*

## ១. អំពីធនាគារ

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា “ធនាគារ“) បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេស ដែលបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ធនាគារគឺជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១ ក្រោមការចុះបញ្ជីការលេខ ០០០០៦៣៨៨ ដែលចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី “ធនាគារជាតិនៃកម្ពុជា” ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។ ភាគហ៊ុនរបស់ធនាគារពីដំបូង ត្រូវបានកាន់កាប់ទាំងស្រុងដោយ ក្រុមហ៊ុន AEON Thana Sinsap (Thailand) Public Company Limited ដែលជាក្រុមហ៊ុនបានចុះបញ្ជីនៅប្រទេសថៃ។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ ធនាគារទទួលបានអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមានសុពលភាពជាអចិន្ត្រៃយ៍។ នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ធនាគារទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មលើការផ្លាស់ប្តូរឈ្មោះពី អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ទៅជាធនាគារ ឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី និងផ្លាស់ប្តូររចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនទៅជា ៨០% ដែលត្រូវបានកាន់កាប់ដោយ AEON Thana Sinsap (Thailand) Public Company Limited និង ២០% ត្រូវកាន់កាប់ដោយ AEON Financial Co.. Ltd. (ហៅកាត់ថា “AFS”)។

នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ ធនាគារទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មដើម្បីកែប្រែរចនាសម្ព័ន្ធភាគហ៊ុនដោយមានការកាន់កាប់ ៥០% ស្មើគ្នារវាង AEON Thana Sinsap (Thailand) Public Company Limited និង AFS។

នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ AFS បានផ្ទេរភាគហ៊ុនទាំងអស់ទៅធនាគារ AFS Corporation Co.. Ltd. ដែលជាក្រុមហ៊ុនមេនៅប្រទេសជប៉ុន។ AFS Corporation Co.. Ltd. ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ AFS។ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០ ធនាគារបានទទួលនូវការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ទៅលើការផ្លាស់ប្តូរ ភាគទុនិក និងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ធនាគារបានទទួលនូវការយល់ព្រមពីក្រសួងពាណិជ្ជកម្ម លើការធ្វើវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន។

ក្រុមហ៊ុនមេធំបំផុតគឺ AEON Co.. Ltd. ដែលបានចុះបញ្ជីនៅប្រទេសជប៉ុន។

សកម្មភាពចម្បងរបស់ធនាគារមានដូចខាងក្រោម៖

- សេវាកម្មកាតឥណទាន
- សេវាកម្មផ្តល់ប្រាក់កម្ចីក្នុងទម្រង់ជាការទិញបណ្តាក់(បង់រំលស់) និងឥណទាន
- សេវាកម្មពាក់ព័ន្ធដទៃទៀតដែលអនុម័តដោយធនាគារជាតិនៃកម្ពុជា។

